CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 15 ខែមករា ឆ្នាំ 2021

ទំនាក់ទំនង ៖ លោក ខេវីន លី (Kevin Lee) ប្រធានផ្នែកកិច្ចការសាធារណៈ នៃការិយាល័យអ្នកចាត់ការក្រុង, 562.570.6811, Kevin.Lee@longbeach.gov

សម្រាប់ការផ្សព្វផ្សាយ ភ្លាមៗ

# ដៃគូសាលាក្រុងឡុងប៊ិច រួមជាមួយ Verizon នាំមកជូនឡុងប៊ិច នូវ សេវាតភ្ជាប់អ៊ីនធឺណែត ឥតខ្សែ ឈានមុខគេ ។

*កិច្ចព្រមព្រៀង ចំពោះបរិយាប័ន្នឌីជីថលឈានមុខ, ការដាក់ឱ្យប្រើប្រាស់ បណ្តាញអ៊ីនធឺណែត ឥតខ្សែ ដោយប្រើអង្គម៉ាស៊ីន ខ្នាតតូច និងដំណោះស្រាយទីក្រុងវៃឆ្លាត*

ទីក្រុងឡុងប៊ិច, រដ្ឋ CA - សាលាក្រុងឡុងប៊ិច បានចាប់ដៃគូ ជាមួយ Verizon សម្រាប់គម្រោងប្រកបដោយនិវានុវត្តន៍មួយ ដែលនឹងផ្តល់អត្ថប្រយោជន៍ ដល់សហគមន៍ និងផ្តល់លទ្ធភាពឱ្យ Verizon អាចពង្រីកវិសាលភាពអង្គម៉ាស៊ីនតូច (small cells) ដើម្បីជំរុញហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ឥតខ្សែ ហើយរៀបមូលដ្ឋាន សម្រាប់សេវា 5G ។ 5G សំដៅលើ ជំនាន់ទីប្រាំ នៃបទដ្ឋានគមនាគមន៍ទូរសព្ទចល័ត ដែលត្រូវបានកំណត់ន័យដោយ ល្បឿនលឿន មានលក្ខណៈកាន់តែទូលំទូលាយជាងមុន និងមានបញ្ហាលាក់មុខ (latency) កម្រិតទាប ជាងបណ្តាញ 4G នាពេលបច្ចុប្បន្ននេះ ។ កិច្ចព្រមព្រៀងនេះ ផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ ដែលជំរុញបន្ថែម លើផែនការខ្សែបណ្តាញមេ, [គំនិតផ្តួចផ្តើមបរិយាប័ន្នឌីជីថល] និង [គំនិតផ្តួចផ្តើមទីក្រុងវៃឆ្លាតរបស់ក្រុង] ។

ចៅហ្វាយក្រុងលោក រ៉ូប៊ើត ហ្គាសៀ (Robert Garcia) បាននិយាយថា «ភាពជាដៃគូនេះ តំណាងឱ្យ ជំហ៊ានដែលអាចចាត់វិធានការបាន ឆ្ពោះទៅរក បរិយាប័ន្នឌីជីថលឈានមុខ ដោយធ្វើការកែលំអគុណភាពជីវិត សម្រាប់ប្រជាពលរដ្ឋ និងជំរុញឡុងប៊ិច ឈានទៅមុខ ជាទីក្រុងវៃឆ្លាត នាំមុខគេមួយ ។»

ជាផ្នែកនៃកិច្ចព្រមព្រៀងនេះ Verizon នឹងផ្តល់ឧបករណ៍ផ្តល់អ៊ីនធឺណែត 100 Mi-Fi (hotspot) ដែលដាក់ឱ្យដំណើរការ ក្នុងរយៈពេលផ្តល់សេវាបួនឆ្នាំ និងថ្លៃ $50,000 ជូនទៅ [មូលនិធិបណ្ណាល័យសាធារណៈ ឡុងប៊ិច] ដែលនឹងត្រូវប្រើប្រាស់ ដើម្បីទិញសៀវភៅ Chromebooks ។ ជាផ្នែកនៃគំនិតផ្តួចផ្តើមបរិយាប័ន្នឌីជីថលរបស់ក្រុង [បណ្ណាល័យសាធារណៈឡុងប៊ិច] នឹងអនុវត្ត កម្មវិធីពិនិត្យឧបករណ៍ (device check-out program) សម្រាប់ប្រជាពលរដ្ឋឡុងប៊ិច ។

លោក ហ្គ្លេនដា វិលលៀម (Glenda Williams) ជាប្រធានផ្នែកសេវា បានគូសបញ្ជាក់ថា «យើងខ្ញុំមានមោទកភាព ចំពោះកិច្ចព្រមព្រៀងនេះ ដែលកិច្ចព្រមព្រៀងនេះ នឹងគាំទ្រដល់ ប្រជាពលរដ្ឋវ័យក្មេងបំផុត របស់ឡុងប៊ិចយើង ក្នុងអំឡុងពេលនៃការសិក្សា តាមអ៊ីនធឺណែត ជាកំហិតនេះ

និងប្រជាពលរដ្ឋផ្សេងៗ ទៀតផងដែរ ។» «ឧបករណ៍ផ្តោតលើសិស្ស-និស្សិត មានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ភាពជោគជ័យ របស់អ្នកដែលត្រូវការ បច្ចេកវិទ្យា និងអ៊ីនធឺណែត»។

ខាធឺរីន អាហ្សា (Katherine Azar) ជានាយកប្រតិបត្តិមូលនិធិបណ្ណាល័យសាធារណៈ ឡុងប៊ិច បានលើកឡើងថា « hotspots និង Chromebooks ដែលនឹងដាក់ឱ្យសិស្ស-និស្សិតអាចប្រើប្រាស់បាននេះ នឹងជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រុង ដើម្បីផ្សារភ្ជាប់បំណែកឌីជីថល ។»

ដំណោះស្រាយទីក្រុងឆ្លាតវៃ ក៏នឹងត្រូវបានគាំទ្រ ជាផ្នែកនៃកិច្ចព្រមព្រៀងនេះដែរ ។ ក្នុងរយៈពេល 24 ខែ នឹងផ្តល់សេវាផ្នែករឹង និងផ្នែកទន់ សម្រាប់ការវិភាគសុវត្ថិភាព នៅចំណុចផ្លូវកាត់គ្នា ដើម្បីផ្តល់មគ្គុទេសក៍ លើការកែលំអសុវត្ថិភាពចរាចរណ៍ ព្រមទាំងការប្រមូលទិន្នន័យកកស្ទះចរាចរណ៍ និងគំនិតយល់ដឹង អំពីការកាត់បន្ថយ ដើម្បីជួយក្រុង ឱ្យអាចយល់ដឹង និងធ្វើការកែលំអ លំហូរចរាចរណ៍ សម្រាប់ច្រកផ្លូវ ចំនួន 10 និង ក្នុងរយៈចម្ងាយ 30 ម៉ៃយ៍ ។

វើរីហ្សុន (Verizon) ក៏នឹងតម្លើង ដោយឥតគិតថ្លៃ លើប្រព័ន្ធអង់តែនចែកចាយ (DAS) នៅអាកាសយានដ្ឋាន និងនៅមជ្ឈមណ្ឌលសន្និសីទ ផងដែរ ។ ប្រព័ន្ធ DAS នឹងបង្កើន បទពិសោធន៍របស់អ្នកប្រើប្រាស់ អ៊ីនធឺណែត ឥតខ្សែ បានយ៉ាងច្រើនអនេក ។

Verizon នឹងទូទាត់ប្រាក់ឱ្យក្រុង $100 ក្នុងមួយបង្គោល ជារៀងរាល់ឆ្នាំ ក្នុងរយៈពេល 20 ឆ្នាំ ក្នុងចំនួនរហូតដល់ 400 បង្គោល, ភ្លើងបំភ្លឺផ្លូវ ឬ ទ្រព្យផ្សេងៗ ទៀត ដែលក្រុងកាន់កាប់ ហើយក្រុងបានព្រមព្រៀងជំរុញល្បឿនសំណើសុំការអនុញ្ញាត ទាំងសម្រាប់អង្គម៉ាស៊ីនតូច នៅលើបង្គោល និងខ្សែតភ្ជាប់ ។ ក្រុងបានអនុម័ត បទដ្ឋានរូបភាព សម្រាប់បង្គោលទាំងនេះ អនុលោមតាមច្បាប់រដ្ឋ និងសហព័ន្ធ ។ ក៏នឹងផ្តល់ជូនក្រុង ដោយឥតគិតថ្លៃ នូវរង្វង់បណ្តាញខ្សែតភ្ជាប់ ជាបន្តគ្នា ក្នុងរយៈចម្ងាយជិត ប្រាំបួនម៉ៃយ៍ ដើម្បីប្រើប្រាស់ សម្រាប់ការអភិវឌ្ឍបណ្តាញខ្សែរបស់ខ្លួន ភ្ជាប់ទៅសម្បទានានា នៅទូទាំងទីក្រុង ។ ហេដ្ឋារចនាសម្ព័ន្ធខ្សែនេះ ជាសម្បត្តិផ្នែកប្រតិបត្តិការ និងជាយុទ្ធសាស្ត្រ យ៉ាងសំខាន់ របស់ក្រុង ដែលរួមគ្នា ជាមួយបុគ្គលិកក្រុង សម្រួលការផ្តល់សេវា ដល់ប្រជាពលរដ្ឋ ធុរកិច្ច និងទេសចរ ។

**អំពីទីក្រុងឡុងប៊ិច**

ដោយជាទីលំនៅ សម្រាប់ប្រជាពលរដ្ឋ ប្រមាណ 480,000 នាក់ ទីក្រុងឡុងប៊ិច ប្រកបដោយនវានុវត្តន៍ និងជាម្ចាស់ ពហុជ័យលាភី ផ្តល់ជូន សម្បទាបម្រើជីវភាពរស់នៅ របស់ទីក្រុងមេត្រូប៉ូលីតាន ធំៗ លំដាប់ពិភពលោក ខណៈដែលរក្សាបាន រសនិយមរឹងមាំ នៃភូមិស្ថាន លក្ខណៈឯកត្តជន និងមានភាពចម្រុះ នៅប្រទាក់ក្រឡាគ្នា តាមបណ្តោយឆ្នេរកាលីហ្វ័រញ៉ា ។ ក្នុងនាមជាទីក្រុងផ្តល់សេវាពេញលេញ ឡុងប៊ិចជាទីលំនៅ របស់ ឃ្វីម៉ារី (Queen Mary) ជលដ្ឋានប៉ាស៊ីហ្វិក សារមន្ទីរ និងមហោស្រព មួយចំនួន មណ្ឌលសិក្សា ចំណាត់ថ្នាក់ខ្ពស់ អាកាសយានដ្ឋានឡុងប៊ិច ផែឡុងប៊ិច ព្រមទាំង អគារលំនៅដ្ឋានក្រុង ជាម្ចាស់ជ័យលាភី ជាច្រើនកន្លែង សេវាសុខាភិបាល សេវាឧទ្យាន ការកំសាន្ត និងសមុទ្រ សេវាអភិវឌ្ឍន៍ និងសេវាផ្សេងៗ ទៀត ។ ទីក្រុងក៏មានសាកលវិទ្យាល័យ និងមហាវិទ្យាល័យក្រុង ដែលទទួលបានការគោរពខ្ពស់, មន្ទីរពេទ្យចំនួនប្រាំ, កសិដ្ឋានប្រវត្តិសាស្ត្រចំនួនពីរ, ទីវាលវាយកូនហ្គោលចំនួនប្រាំ, ឧទ្យានចំនួន 171 ទីតាំង, ឆ្នេរសមុទ្រប្រាប់សិបម៉ៃយ៍, ផែ, ផ្លូវជិះកង់, និងកម្មវិធីចែករំលែកកង់ ផងដែរ ។

សម្រាប់ព័ត៌មានបន្ថែមទៀត អំពីទីក្រុងឡុងប៊ិច សូមចូលទៅ http://longbeach.gov/ សូមតាមយើងខ្ញុំ នៅលើបណ្តាញសង្គម ដើម្បីទទួលបានព័ត៌មានចុងក្រោយបំផុតនានា ៖ Facebook, Twitter, Instagram និង YouTube ។

**អំពីបណ្ណាល័យសាធារណៈ ឡុងប៊ិច**

បណ្ណាល័យសាធារណៈ ឡុងប៊ិច ដែលបានបង្កើតឡើង នៅឆ្នាំ 1896 បម្រើជូន ទីក្រុងចម្រុះលក្ខណៈ ដែលមានប្រជាពលរដ្ឋ ជិតកន្លះលាននាក់ ។ ប្រព័ន្ធបណ្ណាល័យសាធារណៈ ឡុងប៊ិច រួមមាន បណ្ណាល័យចំបង និងបណ្ណាល័យ តាមភូមិស្ថាន ចំនួនដប់មួយ ព្រមទាំង បណ្ណាល័យ លើអ៊ីនធឺណែត យ៉ាងរស់រវើក ។ នៅរដូវក្តៅ ឆ្នាំ 2017, បណ្ណាល័យសាធារណៈ ឡុងប៊ិច ទទួលបានជ័យលាភីមេដាយថ្នាក់ជាតិ សម្រាប់សេវាបណ្ណាល័យ និងសារមន្ទីរ ដោយមានការទទួលស្គាល់ លើកិច្ចសហការសហគមន៍ ប្រកបដោយជោគជ័យ, កម្មវិធី STEM (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា) និងកម្មវិធីផ្តោតលើអក្សរសាស្ត្រ ប្រកបដោយនវានុវត្តន៍ សម្រាប់ប្រជាពលរដ្ឋឡុងប៊ិច ។ ដោយមានការផ្តោតលើ ការផ្តល់លទ្ធភាពទទួលបាន ព័ត៌មាន និងការគាំទ្រ ដោយឥតគិតថ្លៃ និងដោយស្មើភាពគ្នា សម្រាប់ការរៀន ពេញមួយជីវិតនោះ បណ្ណាល័យផ្តល់ជូន សៀវភៅ ឯកសារផ្សព្វផ្សាយ ទិន្នន្នដ្ឋាន អ៊ីនធឺណែត មជ្ឈមណ្ឌលសិក្សាលក្ខណៈគ្រួសារ លំហរអ្នកធ្វើ និងព្រឹត្តិការណ៍ផ្សេងៗ ជាច្រើនទៀត ដែលមានចាប់ពី វគ្គនិទានរឿង រហូតដល់ កម្មវិធីវប្បធម៌ និងសិក្ខាសាលាលក្ខណៈអប់រំ ។

សម្រាប់ព័ត៌មានបន្ថែមទៀត សូមចូលទៅ http://www.lbpl.org/, “ចុចចូលចិត្ត (Like)” ទំព័រ Long Beach Public Library នៅលើ Facebook, ហើយ តាមទំព័រឈ្មោះនេះ នៅលើ Twitter និង Instagram។

**អំពីមូលនិធិបណ្ណាល័យសាធារណៈ ឡុងប៊ិច**

មូលនិធិបណ្ណាល័យសាធារណៈ ឡុងប៊ិច ដែលជាអង្គការមិនរកប្រាក់ចំណេញ 501(c)3 ឯករាជ្យមួយ ផ្តល់ការគាំទ្រ ដល់ការលើកកម្ពស់ បណ្ណាល័យចំបង និងសាខាតាមភូមិស្ថាន ចំនួន 11 របស់បណ្ណាល័យសាធារណៈ ឡុងប៊ិច ហើយលើកទឹកចិត្ត ឱ្យមានការប្រើប្រាស់សេវាបណ្ណាល័យ និងអប់រំ សម្រាប់សមាជិកទាំងអស់ របស់សហគមន៍ ។ LBPLfoundation.org

**អំពីវេរីហ្សុន (Verizon)**

ក្រុមហ៊ុន Verizon Communications Inc. (NYSE, Nasdaq: VZ) ត្រូវបានបង្កើតឡើង នៅថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2000 ហើយនឹងធ្វើការអបអរសាទរ ខួបទី 20 ឆ្នាំ ក្នុងនាមជា អ្នកផ្តល់សេវាបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មាន ព្រមទាំង ផលិតផល និងសេវាកំសាន្ត នាំមុខគេមួយ នៅលើពិភពលោក ។ ក្រុមហ៊ុននេះផ្តល់ សេវាទិន្នន័យ វីដេអូ និងសម្លេង ព្រមទាំង ដំណោះស្រាយ ចំពោះបណ្តាញ និងវេទិកា ដែលទទួលបានជ័យលាភី របស់ខ្លួន តបតាមតម្រូវការរបស់អតិថិជន លើការផ្លាស់ទី ការតភ្ជាប់បណ្តាញដែលអាចទុកចិត្តបាន សុវត្ថិភាព និងការគ្រប់គ្រងបាន ។

###